Student/Registration Number | | | | | | | | | | | Centre Number | | | | | | |

**2021 PUBLIC EXAMINATION**

# Khmer

## Continuers Level

**Tuesday 19 October: 2 pm Australian Eastern Daylight Time**

Reading Time: 10 minutes
Writing Time: 2 hours and 30 minutes

- *You have 10 minutes to read all the papers and to familiarise yourself with the requirements of the questions. You MUST NOT write during this time.*
- *Monolingual and/or bilingual printed dictionaries may be consulted during the reading time and also during the examination.*

## Section 1: Listening and Responding (30 marks)

**Instructions to Students**

1. Allow approximately 40 minutes for Section 1.
2. Write all your answers to the questions in Section 1 in this booklet using black or blue pen. Space is provided for you to make notes.
3. You must answer ALL questions in Part A and Part B.
4. Answer Part A in ENGLISH and Part B in KHMER.
5. Write your student/registration number and the centre number (if required) on the front cover of this booklet.
6. All question booklets will be collected at the end of the examination.

*© SACE Board of South Australia 2021*

**Part A** (Questions 1 to 3)
(15 marks)

---

*Your response will be assessed on how well you:*

- *understand general and specific aspects of texts by identifying and analysing information and convey the information accurately and appropriately.*

---

You will hear THREE texts. Each text will be played twice. There will be a short break between the first and second playings of each text. You may make notes at any time.

Listen carefully to each text and then answer the questions in ENGLISH.

**Marks**

You may make notes in this space. These notes will NOT be assessed.

**Text 1**

1. (a) What is the purpose of this announcement? **2**

______________________________

______________________________

______________________________

______________________________

(b) Why is this event significant? **2**

______________________________

______________________________

______________________________

______________________________

Marks | You may make notes in this space. These notes will NOT be assessed.

**Text 2**

2. (a) According to the text, what is the responsibility of a woman's parents when a man has expressed an interest in marrying her, and how do parents traditionally fulfil their responsibility? **4**

(b) What is the relationship between the two speakers? Support your answer with evidence from the text. **2**

Marks

You may make notes in this space. These notes will NOT be assessed.

**Text 3**

3. How do the presenters feel about the singing competition? Support your answer with evidence from the text. 5

**Part B** (Questions 4 to 6)
(15 marks)

---

*Your response will be assessed on how well you:*

- *understand general and specific aspects of texts by identifying and analysing information and convey the information accurately and appropriately.*

---

You will hear THREE texts. Each text will be played twice. There will be a short break between the first and second playings of each text. You may make notes at any time.

Listen carefully to each text and then answer the questions in KHMER.

**Marks** | You may make notes in this space. These notes will NOT be assessed.

**Text 4**

4. (a) Why is Mr Sokun Chea invited to speak? **2**

ហេតុអ្វីបានជាលោកជា សុគុណត្រូវបានគេអញ្ជើញអោយមកនិយាយ?

___

___

___

___

(b) How appropriate for the occasion is Mr Heng Kim’s style of speech? Support your answer with evidence from the text. **3**

តើសំដីនិយាយរបស់លោកគឹម ហេងសមស្របទៅនឹងកាលៈទេសៈនេះយ៉ាងណា? ចូរគាំទ្រចម្លើយរបស់អ្នកដោយដកស្រង់ភស្តុតាងចេញពីអត្ថបទ។

___

___

___

___

___

___

**Marks**

You may make notes in this space. These notes will NOT be assessed.

**Text 5**

5. Why do you think that Mr Sary was awarded Farmer Role Model of the Year for the district? Support your answer with evidence from the text. **5**

តើហេតុអ្វីបានជាអ្នកយល់ថាលោកសារីត្រូវបានទទួលរង្វាន់ជា
កសិករគំរូប្រចាំឆ្នាំសម្រាប់តំបន់? ចូរគាំទ្រចម្លើយរបស់អ្នកដោយ
ស្រង់ភស្តុតាងចេញពីអត្ថបទ។

**Marks**

You may make notes in this space. These notes will NOT be assessed.

**Text 6**

6. (a) Explain why the boy is fanning tourists on the steps and is not at school. **2**

ចូរពន្យល់ថាហេតុអ្វីបានជាកុមារបក់ផ្លិតអោយទេសចរតាមកាំជណ្ដើរ ហើយមិនទៅសាលារៀន។

(b) How does the woman's attitude change during the conversation? Support your answer with evidence from the text. **3**

តើអាកប្បកិរិយារបស់ស្ត្រីផ្លាស់ប្ដូរយ៉ាងណាខ្លះក្នុងពេលសន្ទនា? ចូរគាំទ្រចម្លើយរបស់អ្នកដោយស្រង់ភស្តុតាងចេញពីអត្ថបទ។

**End of Section 1**

**KHMER (CONTINUERS) EXAMINATION 2021**

**Section 1: Listening and Responding**

## PART A

***Text 1***

សមាគមខ្មែរអូស្ត្រាលី សូមអញ្ជើញមិត្តភក្តិនិងគ្រួសារខ្មែរទាំងអស់មកចូលរួមក្នុងពិធីសម្ពោធបដាខ្មែរ ដែលរៀបរាប់អំពីទុក្ខវេទនារបស់ជនភៀសខ្លួនខ្មែរយើងពេលដែលបានមករស់នៅក្នុងប្រទេសអូស្ត្រាលី។ បដានេះនឹងដាក់តាំងជាអចិន្ត្រ័យនៅក្នុងសារមន្ទីរអន្តោប្រវេសន៍។

កិច្ចសម្ពោធនេះនឹងប្រព្រឹត្តទៅនៅសារមន្ទីរអន្តោប្រវេសន៍ អាស័យដ្ឋាន 154 Bath Street, Darwin នៅថ្ងៃសៅរ៍ ទី២៣ ខែតុលា វេលាម៉ោង១ សាមសិបនាទីថ្ងៃ។

ពត៌មានបន្ថែម សូមទាក់ទងមកលោក ទូច សារិន ទូរស័ព្ទលេខ ០៤៩១ ៥៧២ ៩៨៣។

*Text 2*

សិស្ស ជំរាបសួរលោកគ្រូ។ តើខ្ញុំអាចសួរលោកគ្រូបន្តិចបានទេ?

លោកគ្រូ ជំរាបសួរស៊ីថា។ មានអីសួរមកចុះ។

សិស្ស សូមលោកគ្រូមេត្តាប្រាប់ខ្ញុំបន្តិចបានទេអំពីការរកគូស្រករនៅប្រទេសកម្ពុជា?

លោកគ្រូ មានអី។ តាមទំនៀមទំលាប់ បុរសដែលចង់រៀបការជាមួយអ្នកណាម្នាក់ត្រូវតែមានឋានៈយ៉ាងហោចណាស់ស្មើនឹងមនុស្សស្រី បើមិនដូច្នោះទេ ឪពុកម្តាយខាងស្រីគេមិនយល់ព្រមអោយរៀបការទេ ជាពិសេសចំពោះស្រីស្អាតរស់នៅក្នុងត្រកូលអ្នកមាន។

ស៊ីថា តើឋានៈបែបណាដែលលោកគ្រូមានប្រសាសន៍?

លោកគ្រូ មុខរបរ ស្អាត អាយុ ចរិយាសម្បត្តិ និងទ្រព្យសម្បត្តិ។ មាតាបិតាត្រូវតែដឹងប្រាកដថាកូនស្រីរបស់គាត់នឹងមានជីវភាពល្អក្រោយពេលរៀបការរួច។ កុំភ្លេចថា គ្មាននារីណាម្នាក់ដែលអាចមានសង្សារមុនរៀបការទេណ៎ា។

ស៊ីថា បើនារីមិនអាចមានសង្សារទេ ធ្វើម៉េចអោយមាតាបិតាគេដឹងថាបុរសនោះមានចរិយាសម្បត្តិល្អ?

លោកគ្រូ មាតាបិតាខាងស្រីត្រូវតែសើបសួរអំពីពូជពង្សគ្រួសារខាងបុរស តាមរយៈសួរអ្នកដទៃ។ កាលពីជំនាន់ដើម មាតាបិតាខាងស្រីមួយចំនួនតម្រូវអោយបុរសមកស្នាក់នៅ និងធ្វើការជាមួយគ្រួសារខាងស្រីរហូតទាល់តែមាតាបិតាខាងស្រីពេញចិត្តបុរសនោះ។

ស៊ីថា ទាំងអស់នេះវាខុសពីស្ថានភាពនៅប្រទេសអូស្ត្រាលីខ្លាំងណាស់ លោកគ្រូ?

លោកគ្រូ មែនហើយ ប៉ុន្តែភាគច្រើនវានៅតែអញ្ចឹងនៅប្រទេសកម្ពុជា។

***Text 3***

រក្សា អស់លោកលោកស្រីជាទីមេត្រី ខ្ញុំឈ្មោះរក្សា ហើយនេះគឺកញ្ញាម៉ូណា។ យើងទាំងពីរនាក់មានកិត្តិយសដែលបានធ្វើជាពិធីករនារាត្រីផ្តាច់ព្រ័ត្រនៃការប្រឡងចំរៀង។ កញ្ញាម៉ូណា តើអ្នកនាងមានអារម្មណ៍យ៉ាងណាដែរ?

ម៉ូណា ខ្ញុំមានអារម្មណ៍សប្បាយរីករាយនិងរំភើបជាខ្លាំងដែលបានឃើញទស្សនិកជនយ៉ាងច្រើនកុះករទាំងក្មេងទាំងចាស់បានមកទស្សនានារាត្រីនេះ។ លោករក្សា តើយើងមានបេក្ខជនប៉ុន្មាននាក់នៅរាត្រីនេះ?

រក្សា យើងមានបេក្ខជនចំនួន១០នាក់។ ការប្រកួតចំរៀងលើកនេះមានកំរិតខ្ពស់ ព្រោះបេក្ខជនទាំងអស់នេះជាជើងឯកដែលត្រូវបានគេចំរាញ់ចេញពីអ្នកចំរៀងបីពាន់នាក់ដែលបានមកចុះឈ្មោះប្រកួត។

ម៉ូណា ខ្ញុំកោតសរសើរមែនទែន។ លោករក្សា តើយើងមានកម្មវិធីអ្វីខ្លះនៅរាត្រីនេះ?

រក្សា យើងនឹងចាប់ផ្តើមពីរបាំជូនពរដើម្បីជូនពរដល់បេក្ខជនទាំងអស់មានសំណាងល្អគ្រប់ៗគ្នា។

ម៉ូណា វាជាការសមស្របណាស់!

រក្សា បន្ទាប់មកយើងចាប់ផ្តើមបើកការប្រកួតវគ្គទីមួយ។ បេក្ខជននីមួយៗនឹងច្រៀងចំរៀងដែលគេជ្រើសរើស។ បន្ទាប់មកនឹងមានការសំដែងសិល្បៈសៀក។

ម៉ូណា អ៊ូ! ប្រាកដជាល្អមើលមែនទែន ហើយបន្ទាប់មកទៀត?

រក្សា យើងនឹងចាប់ផ្តើមប្រកួតជាវគ្គទីពីរដែលអ្នកចំរៀងនឹងច្រៀងចំរៀងទីពីររបស់ខ្លួន។ ហើយបន្ទាប់មកនឹងមានឆាកកំប្លែងមួយ ខណៈដែលគណៈកម្មការកំពុងធ្វើសេចក្តីសម្រេចចិត្ត។ នៅទីបញ្ចប់ ប្រធានគណៈកម្មការនឹងប្រកាសលទ្ធផលអ្នកឈ្នះពីលេខមួយដល់លេខប្រាំ។ អ្នកឈ្នះទាំងអស់នឹងបានទទួលរង្វាន់គ្រប់ៗគ្នា។

ម៉ូណា ហ៊ឹម! ខ្ញុំចង់ដឹងណាស់ហ្ន៎ តើអ្នកណាជាអ្នកមានសំណាង! ខ្ញុំមិនអាចរង់ចាំបានទេ!

**PART B**

***Text 4***

អស់លោកលោកស្រីជាទីគោរព ខ្ញុំបាទឈ្មោះគឹម ហេង ជាលេខាធិការនៃក្រុមភ្លេងបុរាណខ្មែរ។ ជាដំបូង ខ្ញុំបាទសូមស្វាគមន៍អស់លោកលោកស្រីដែលបានមកចូលរួមប្រជុំមហាសន្និបាទប្រចាំឆ្នាំនេះ។ តាងនាមគណៈកម្មការ ខ្ញុំបាទសូមអរគុណជាអនេកដល់វត្តមានអស់លោកលោកស្រីនាល្ងាចនេះ។

មាតិការប្រជុំមានដូចតទៅ៖ របាយការណ៍លោកប្រធាន របាយការណ៍ហិរញ្ញិក បោះឆ្នោតកែលក្ខណ្ឌិកៈ និងទីបញ្ចប់ បោះឆ្នោតជ្រើសរើសប្រធានថ្មីសម្រាប់អាណត្តិ២ឆ្នាំទៅមុខទៀត។

ឥឡូវនេះខ្ញុំបាទសូមអញ្ជើញលោកប្រធានមកធ្វើរបាយការណ៍របស់គាត់។
សូមស្វាគមន៍លោកជា សុគុន។

(Applause)

***Text 5***

អ្នកសំភាស សួស្តី លោកសារី ហើយសូមជួយអបអរសាទរដែលបានជាប់ជាកសិករគំរូសម្រាប់តំបន់យើងឆ្នាំនេះ។

សារី សួស្តី។ អរគុណ។ វាជាការភ្ញាក់ផ្អើលខ្លាំងណាស់។

អ្នកសំភាស តើលោកធ្លាប់បានប្រកបរបរធ្វើស្រែចំការតាំងពីពេលណាមក?

សារី ខ្ញុំធ្លាប់បានជួយឪពុកម្តាយខ្ញុំធ្វើស្រែតាំងពីខ្ញុំនៅក្មេងម្ល៉េះ។ ក្រោយពីខ្ញុំបានរៀបការរួច ឪពុកម្តាយខ្ញុំបានអោយស្រែខ្ញុំមួយកន្លែង ហើយបីឆ្នាំមុន ខ្ញុំបានចាប់ផ្តើមធ្វើចំការម្នាស់។

អ្នកសំភាស អ៊ូ! លោកជាអ្នកខំធ្វើការខ្លាំងណាស់ណ្ហ៎។ តើលោកប្រើបច្ចេកទេសពិសេសអ្វីក្នុងការដាំស្រូវ?

សារី ខ្ញុំមិនប្រើជីណាដែលមិនធម្មជាតិទេ ព្រោះវានាំអោយខូចដី។ ខ្ញុំយកស្លឹកឈើ ចំបើង និងអាចម៍គោមកធ្វើជាជីជំនួសវិញ។ វាថោកហើយជាជីធម្មជាតិ ហើយវាល្អសម្រាប់បរិដ្ឋានផង។ ខ្ញុំក៏មើលថែស្រែរបស់ខ្ញុំរាល់ថ្ងៃដែរដោយដកស្មៅ ចាប់សត្វល្អិត និងប្រយ័ត្នមើលទឹកអោយមានគ្រប់គ្រាន់ក្នុងស្រែផង។

អ្នកសំភាស ម៉េចបានជាលោកចង់ដាំម្នាស់? តើលោកមានពេលវេលាគ្រប់គ្រាន់សម្រាប់ធ្វើចំការទេ?

សារី យើងមិនចាំបាច់ធ្វើការនៅស្រែរាល់ថ្ងៃពេញមួយឆ្នាំទេ។ ក្រោយពេលស្ទូងរួចនារដូវភ្លៀង កសិករភាគច្រើនមានពេលសម្រាប់ប្រកបរបរអ្វីផ្សេងបានរហូតដល់រដូវច្រូតកាត់ឯណោះ។ ដូច្នេះហើយបានជាខ្ញុំឆ្លៀតដាំម្នាស់ដើម្បីបង្កើនប្រាក់ចំណូលរបស់ខ្ញុំ។ ខ្ញុំបានសាកដាំពូជផ្សេងៗគ្នាដើម្បីអោយដឹងថាតើពូជណាមួយប្រសើរសម្រាប់ដីរបស់ខ្ញុំ។

អ្នកសំភាស អរគុណលោកសារីដែលបានអនុញ្ញាតអោយខ្ញុំសំភាសលោក។

សារី អរគុណ មិនអីទេ។

*Text 6*

Tourist អ៊ូយ ហត់ណាស់ ក្តៅពេក! អង្គុយសិនហើយ។ ឡើងច្រើនកាំហើយ។

Boy លោកមីង សម្រាកសិនចុះ ចាំខ្ញុំបក់ជូន។

Tourist អ៊ូ! មិនបាច់ទេ។ មីងមិនបានពឹងឯងឯណា។

Boy កុំព្រួយអីលោកមីង លោកមីងអាចបង់អោយខ្ញុំតិចប៉ុនណាក៏បានដែរ។ ហើយបើមិនបង់អោយខ្ញុំ ខ្ញុំក៏មិនថាអីដែរ។

Tourist ហើយម៉ិចបានឯងមិនទៅសាលារៀនថ្ងៃនេះ?

Boy ខ្ញុំមិនអាចទៅសាលាបានទេលោកមីង ព្រោះយើងមិនមានលុយគ្រប់គ្រាន់សម្រាប់បង់ថ្លៃសាលាទេ ហើយម្យ៉ាងទៀត ខ្ញុំត្រូវជួយប៉ាខ្ញុំរកលុយផង។

Tourist ចុះឪពុកម្តាយឯងមិនធ្វើការទេអ្វី?

Boy ពុកខ្ញុំជាអ្នកធាក់ស៊ីក្លូ។ គាត់មិនរកលុយបានប៉ុន្មានទេ។

Tourist ចុះម្តាយឯងវិញនុះ?

Boy ម៉ែខ្ញុំ គាត់ធ្វើការនៅផ្ទះ និងមើលថែកូនប្រុសស្រី៥នាក់ទៀត។

Tourist ឯងរកបានប៉ុន្មានដែរក្នុងមួយថ្ងៃ ដោយបក់ផ្លិតអោយទេសចរ?

Boy នៅថ្ងៃណាដែលមានទេសចរច្រើន ខ្ញុំអាចរកបាន៤០០០រៀល វាស្មើនឹងមួយដុល្លារអាមេរិក។ ប៉ុន្តែបើថ្ងៃស៊យវិញ តែមួយពាន់រៀលមិនបានផង។

Tourist ហ៊ឹម! មីងអាណិតឯងណាស់។ អញ្ចឹងចាំទៅដល់លើ មីងអោយឯងពីរដុល្លារណ៎ាអ៊ូខេ។

Boy ខ្ញុំអរគុណលោកមីងខ្លាំងណាស់។ លោកមីងចិត្តល្អ ហើយខ្ញុំស្រឡាញ់លោកមីងមែនទែន។ ទិដ្ឋភាពមើលពីលើកំពូលភ្នំស្អាតមែនទែន លោកមីង។

Student/Registration Number | | | | | | | | | | | Centre Number | | | | | | |

## 2021 PUBLIC EXAMINATION

# Khmer

## Continuers Level

## Section 2: Reading and Responding (25 marks)

**Instructions to Students**

1. Allow approximately 1 hour and 10 minutes for Section 2.
2. Write all your answers to the questions in Section 2 in this booklet using black or blue pen. Space is provided for you to make notes.
3. You must answer ALL questions in Part A and Part B.
4. Answer Part A in ENGLISH and Part B in KHMER.
5. Write your student/registration number and the centre number (if required) on the front cover of this booklet.
6. All question booklets will be collected at the end of the examination.

*© SACE Board of South Australia 2021*

**Part A** (Questions 7 and 8)
(10 marks)

---

*Your response will be assessed on how well you:*

- *understand general and specific aspects of texts (for example, by comparing, contrasting, summarising, and/or evaluating) and convey the information appropriately.*

---

7. Read the text and then answer in ENGLISH the question that follows.

## មធ្យោបាយដ៏ល្អបំផុតដើម្បីធ្វើដំណើរទៅទីក្រុងសៀមរាប

ការទស្សនាប្រទេសកម្ពុជានឹងមិនបានសព្វគ្រប់លុះត្រាតែអ្នកបានទៅមើលប្រាសាទអង្គរវត្តនៅខេត្តសៀមរាបដែលជាទស្សនីយភាពមិនអាចបំភ្លេចបាន។ សៀមរាបឋិតនៅចម្ងាយ៥ម៉ោងពីទីទីក្រុងភ្នំពេញបើធ្វើដំណើរតាមឡានបាស់ ប៉ុន្តែមធ្យោបាយធ្វើដំណើរដ៏រីករាយជាងនេះគឺការធ្វើដំណើរតាមកាណូត។ វាអស់ថ្លៃថោកនិងរហ័សជាងឡានបាស់ និងយើងអាចសម្រាកកាយបានល្អជាង ហើយអ្នកនឹងបានឃើញនូវសកម្មភាពទាំងឡាយតាមដងទន្លេមេគង្គដែលអ្នកប្រហែលជាមិនធ្លាប់បានឃើញនៅប្រទេសអូស្ត្រាលីទេ។

កាណូតចាប់ចេញដំណើរពីកំពង់ផែភ្នំពេញរាល់ថ្ងៃនៅម៉ោង៦ព្រឹក។ ការធ្វើដំណើររបៀបនេះកំពុងពេញនិយម ដូច្នេះសូមអ្នកប្រុងប្រៀបរកកន្លែងមួយនៅលើដំបូលកាណូតដើម្បីបានទស្សនាគ្រប់ជ្រុងជ្រោយនូវទស្សនីយភាពដ៏ល្អប្រណីតតាមដងទន្លេដ៏ធំជាងគេនៃប្រទេសកម្ពុជា។

នៅតាមសងខាងនៃច្រាំងទន្លេមានសួនបន្លែជាច្រើន រួមជាមួយអ្នកចំការធ្វើការយ៉ាងសកម្មដកស្មៅ កាប់បំផុសដី និងស្រោចដំណាំរបស់គេ។ អ្នកនេសាទកំពុងចែវទូក ដែលធ្វើអំពីដើមត្នោត យឺតៗឆ្លងកាត់ទន្លេដើម្បីនេសាទត្រីដោយប្រើសំណាញ់។ អ្នកប្រហែលជាអាចឃើញត្រីក្នុងទន្លេខ្លះ។ ជួនកាល នៅពេលមេឃខៀវស្រងាត់ស្រឡះល្អ ហ្វូងបក្សីនឹងហើរបណ្តើរគ្នាជាជួរៗប្រណាំងនឹងកាណូត។ អ្នកក៏អាចនិយាយគ្នាលេងជាមួយនឹងអ្នកដំណើរដទៃទៀតបានក្នុងបរិយាកាសមិត្តភាពបំផុត។

បួនម៉ោងក្រោយមក អ្នកមកដល់ភ្នំក្រោមដើម្បីរៀបខ្លួនទៅទីក្រុងសៀមរាបដោយមិនអស់កំឡាំងដោយសារថ្លង់នឹងសំឡេង និងរលាក់ផ្លូវដូចការជិះឡានបាស់ឡើយ។

QUESTION

**Marks**

How does the author encourage readers to travel from Phnom Penh to Siem Reap by boat rather than by bus? Support your answer with evidence from the text. **5**



PLEASE TURN OVER

8. Read the text and then answer in ENGLISH the question that follows.

សួស្ដីសុវណ្ណា!

ខ្ញុំសង្ឃឹមថាពត៌មាននេះនឹងមានប្រយោជន៍ដល់កិច្ចការសាលារបស់ឯង។

ថ្ងៃច័ន្ទ ទី៩ ខែវិច្ឆិកាជាថ្ងៃបុណ្យអបអរសាទរឯករាជ្យជាតិនៅប្រទេសកម្ពុជា។ ឆ្នាំនេះ ខ្ញុំមានភព្វសំណាងបានទៅចូលរួមពិធីនោះជាមួយគ្រួសារខ្ញុំ។ យើងបានទៅមើលការដង្ហែក្បួនតាមដងមហាវិថីនរោត្តមនៅទីក្រុងភ្នំពេញ។ ពេលយើងទៅដល់ មានមនុស្សច្រើនកុះករបានដើររកកន្លែងល្អសម្រាប់ឈរមើលរួចទៅហើយ។ ទីបំផុតយើងបានមកឈរទល់មុខរោងមួយដែលជាកន្លែងព្រះមហាក្សត្រនិងអ្នករដ្ឋការជាន់ខ្ពស់អង្គុយយ៉ាងស្រួលចាំមើលក្បួនដង្ហែ។ យើងមានសំណាងណាស់ដែលបានឃើញព្រះមហាក្សត្រ។

នៅម៉ោង៧ព្រឹកគត់ សំឡេងភ្លេងដែលប្រគំឡើងដោយក្រុមកងរាជអាវុធហត្ថជាសញ្ញាថាពិធីបុណ្យបានចាប់ផ្ដើមហើយ។ វាជាការរំភើបមែនទែន! ក្រុមកងយោធាផ្សេងៗទៀតក៏បានចាប់ផ្ដើមបន្តដើរយ៉ាងទៀងទាត់ស្របនឹងចង្វាក់ភ្លេង។ ទស្សនិកជនភាគច្រើន រួមទាំងយើងផងបានគ្រវីទង់ជាតិខ្មែរហើយស្រែកហ៊ោរយ៉ាងភ្លៀវភ្លាអបអរសាទរដល់ក្រុមដង្ហែក្បួននិងក្រុមភ្លេង។ ក្រសួងរដ្ឋបាលនានាក៏បានបញ្ជូនក្រុមតំណាងរបស់ខ្លួនមកចូលរួមដង្ហែដែរ។ គេទាំងឡាយបានតុបតែងឡានរបស់គេដោយតាំងរូបតំណាងក្រសួងរបស់ខ្លួន។

ថ្ងៃនេះជាថ្ងៃដ៏មហោឡារិករបស់ជនជាតិខ្មែរទូទាំងប្រទេស។ ប៉ុន្តែអ្នកដែលចំណេញជាងគេគឺអ្នកលក់ចំណីនិងអ្នកជាក់ស៊ីក្លូទាំងឡាយដែលអាចសប្បាយរីករាយក្នុងថ្ងៃនេះផង និងរកបានប្រាក់ចំណូលច្រើនជាងថ្ងៃសព្វដងផង។

ចាំអ៊ីមែលមកខ្ញុំបើឯងចង់បានពត៌មានបន្ថែម។

រតនា

QUESTION

**Marks**

According to Rattana, how do the people of Phnom Penh feel about the Independence Day celebration? Support your answer with evidence from the text. **5**

**Part B** (Question 9)
(15 marks)

---

*Your response will be assessed on how well you:*
- *demonstrate understanding of the stimulus text*
- *write text that is appropriate and relevant to context, purpose, and audience*
- *structure and sequence information and ideas*
- *manipulate language structures and vocabulary in Khmer.*

---

9. Read the text and then answer the question in approximately 150 words in KHMER.

## គ្រោះថ្នាក់សម័យថ្មី

នៅក្នុងសង្គមសម័យថ្មី យុវជនភាគច្រើនរបស់យើងចំណាយពេលយ៉ាងច្រើនអង្គុយនៅមុខកុំព្យូទ័រឬលេងល្បែងក្នុងទូរស័ព្ទដៃរបស់គេ មើលក្នុងបណ្ដាញសង្គម ឬស្រាវជ្រាវក្នុងអ៊ិនធ័រណិត។ អំពើនេះវាធ្វើអោយគ្រោះថ្នាក់ដល់សុខភាពរបស់គេ និងទំនាក់ទំនងគ្រួសាររបស់គេ។

តើអ្នកដែលបានសង្កេតឃើញកូនចៅរបស់អ្នកធ្វើសកម្មភាពដូចខាងក្រោមនេះទេ?

១. បង្កើនការប្រើឧបករណ៍ខាងលើ និងប្រើវាដើម្បីសម្រាប់តែបំបាត់ការអផ្សុកប៉ុណ្ណោះ។
២. ខឹងសម្បារនិងមិនសប្បាយចិត្តរាល់ពេលដែលគេមិនអាចប្រើអ៊ិនធ័រណិតបាន ឬពេលទូរស័ព្ទឬកុំព្យូទ័ររបស់គេមានបញ្ហាម្ដងៗ។
៣. ថ្ងូរអំពីការឈឺកដៃ ឈឺក ខ្នង ស្មា ឬស្រវាំងភ្នែកដោយសារតែការប្រើទូរស័ព្ទឬកុំព្យូទ័រច្រើនពេក។
៤. មិនបានទទួលលទ្ធផលនៃការសិក្សាល្អដោយសារតែមានការរំខានក្នុងការសិក្សាច្រើនពេក។
៥. ជៀសវាងការចូលរួមក្នុងសង្គមជាមួយគ្រួសារនិងមិត្តភក្តិ។

បើដូច្នោះមែន អ្នកគួរតែនិយាយជាមួយគាត់អំពីភាពគ្រោះថ្នាក់។ បើសិនជាមិនមានការប្រសើរទេ ចូរអ្នកស្វែងរកជំនួយពីអ្នកឯកទេស។

QUESTION

You have read this article in a local newspaper and have decided to write a letter to the editor conveying your disappointment with the one-sided views in the article and providing your opinion. Write your letter.

អ្នកបានអានអត្ថបទខាងលើក្នុងសារពត៌មានតំបន់មួយ ហើយបានសម្រេចចិត្តសរសេរសំបុត្រមួយផ្ញើទៅចាងហ្វាងនិពន្ធ ដោយបញ្ជាក់ពីការខកចិត្តរបស់អ្នកទៅលើទស្សនៈតែម្ខាងនៅក្នុងអត្ថបទនោះ ហើយនិងផ្ដល់យោបល់របស់អ្នកផង។ ចូរអ្នកសរសេរអត្ថបទរបស់អ្នក។

*You may remove this page from the booklet by tearing along the perforations so that you will have the information in front of you for easy reference.*

You may make notes on this page. These notes will NOT be assessed.

This page is intentionally blank

Question 9

**End of Section 2**

Student/Registration Number | | | | | | | | | | | Centre Number | | | | | |

# 2021 PUBLIC EXAMINATION

# Khmer

## Continuers Level

## Section 3: Writing in Khmer (20 marks)

**Instructions to Students**

1. Allow approximately 40 minutes for Section 3.
2. Write your answer to a question from Section 3 in this booklet using black or blue pen. Space is provided for you to make notes.
3. You must answer ONE question in KHMER.
4. Write your student/registration number and the centre number (if required) on the front cover of this booklet.
5. All question booklets will be collected at the end of the examination.

© SACE Board of South Australia 2021

**Section 3** (Questions 10 to 12)
(20 marks)

---

*Your response will be assessed on how well you:*

- *demonstrate depth of treatment of information, ideas and/or opinions*
- *write text that is appropriate and relevant to context, purpose, and audience*
- *structure and sequence information and ideas*
- *manipulate language structures and vocabulary in Khmer.*

---

Answer ONE question from this section in approximately 250 words in KHMER.

10. The majority of young Cambodian people in Australia live with their parents until they get married. You have been asked by your teacher to prepare a speech to the class about the reasons behind this situation. Write your speech.

    យុវជនខ្មែរភាគច្រើននៅប្រទេសអូស្ត្រាលីរស់នៅជាមួយមាតាបិតារហូតទាល់តែគេបានរៀបមង្គលការរួច។ អ្នកត្រូវបានសាស្ត្រាចារ្យរបស់អ្នកអោយរៀបចំធ្វើសន្ទរកថាក្នុងថ្នាក់មួយអំពីមូលហេតុដែលនៅពីក្រោយស្ថានការណ៍នេះ។ ចូរអ្នកសរសេរសន្ទរកថារបស់អ្នក។

11. You have just finished your first week in your new job, which provides opportunities to use your Khmer language. Write a diary entry reflecting on your experiences.

    អ្នកទើបតែបានធ្វើការរួចនៅអាទិត្យទីមួយនៃការងារថ្មីរបស់អ្នក ដែលផ្តល់ឱកាសអោយអ្នកបានប្រើភាសាខ្មែររបស់អ្នក។ ចូរអ្នកសរសេរកំណត់ហេតុមួយដោយឆ្លុះបញ្ចាំងអំពីបទពិសោធន៍ទាំងឡាយដែលអ្នកបានទទួល។

12. An old Khmer saying is: ‘If you want to know, you should try hard to learn; if you want to be rich, you should try hard to find work.’ Write an article for your community magazine, evaluating the relevance of the saying.

    ឃ្លាបុរាណខ្មែរមួយចែងថា៖ ‘បើចង់ចេះអោយខំរៀន បើចង់មានអោយខំរកការងារធ្វើ’។ ចូរអ្នកសរសេរអត្ថបទមួយសម្រាប់ចុះផ្សាយក្នុងព្រឹត្តិប័ត្រសហគមន៍របស់អ្នក ដោយធ្វើការវាយតម្លៃពីភាពសមស្របនៃឃ្លាបុរាណខ្មែរនេះ។

*You may remove this page from the booklet by tearing along the perforations so that you will have the information in front of you for easy reference.*

You may make notes on this page. These notes will NOT be assessed.

This page is intentionally blank

Question Number:

**End of Section 3**